00700465

E51/11

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 27 / 05 / 2011
ម៉ោង (Time/Heure): 14 : 25
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬអង្គជំនុំជម្រះ : **សាធារណៈ / Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណាបន្ថែមរបស់លោក អៀង សារី លើអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩**

***(គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem))***

---

**ដាក់ដោយ៖**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្តរ៉ា

ចៅក្រមបំរុង Claudia FENZ

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់ខ្លួន (“មេធាវីការពារក្តី”) និងអនុលោមតាមអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា “ការដាក់អញ្ញត្រកម្មបន្ថែម (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem)*)[១] សូមដាក់សារណានេះ បន្ថែមលើអញ្ញត្រកម្មរបស់ខ្លួន ជំទាស់ទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក ដែលបានផ្អែកលើ*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*។ សារណាបន្ថែមនេះនិយាយយោងដោយរួមបញ្ចូលទឡ្ហីករណ៍ទាំងអស់កាលពីលើកមុនដែលមេធាវីការពារក្តីបានយកធ្វើជាសំអាងទាក់ទងទៅនឹងបញ្ហានេះ[២]។

## I. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងបានស្នើឱ្យមេធាវីការពារក្តីកំហិតសារណាបន្ថែមនេះ ត្រឹមតែការឆ្លើយតបទៅនឹងសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[៣] និងជាពិសេសត្រឹមតែលើបញ្ហាថាតើ មេធាវីការពារក្តី “យល់ថា ការជំនុំជម្រះកាលពីឆ្នាំ ១៩៧៩ របស់តុលាការបដិវត្តន៍ប្រជាជន ធ្វើឡើងស្របតាមបទដ្ឋានត្រឹមត្រូវដែរឬទេ រួមទាំងក្របខ័ណ្ឌគតិយុត្តដែលតុលាការនេះលើកយកមកជាបង្អែក”[៤]។

២. អង្គបុរេជំនុំជម្រះសម្រេចថា *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនបានរារាំងការចោទប្រកាន់លោក អៀង សារី នាពេលបច្ចុប្បន្ននេះទេ ពីព្រោះ៖ ក. គោលការណ៍ដែល

---

[១] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុៈ ការដាក់អញ្ញត្រកម្មបន្ថែម (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ) ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ E51/9។

[២] សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី និងការជូនដំណឹងនៃការមិនគោរពតាមអនុស្សរណៈក្រៅផ្លូវការនានា នាពេលអនាគត ដែលត្រូវបានចេញជំនួសឱ្យសេចក្តីសម្រេចមានសំអាងហេតុរបស់តុលាការដែលជាកម្មវត្ថុបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E51/4។ វាបានរួម បញ្ចូលថែមទៀតនូវទឡ្ហីករណ៍ផ្ទាល់មាត់កាលពីមុនទាំងអស់ដែលបានធ្វើលើបញ្ហានេះ។ សូមមើល ប្រតិចារឹក - សវនាការស្តីពីការឃុំខ្លួនបណ្តោះអាសន្ន - ពីថ្ងៃទី ១ ដល់ថ្ងៃទី ៤ គឺពីថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៨ - ដល់ថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០០៨។

[៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 (“សាលដីកា អបជ”)។

[៤] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុៈ ការដាក់អញ្ញត្រកម្មបន្ថែម (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ) ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ E51/9។

បានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("CPC") អនុវត្តដើម្បីរារាំងការចោទប្រកាន់ថ្មីៗតែនៅក្នុងករណី ដែលការចោទប្រកាន់កាលពីមុនៗត្រូវបានសម្រេចឱ្យរួចខ្លួនជាស្ថាពរ[៥] ខ. គោលការណ៍ដូចបានបញ្ជាក់នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") មានអានុភាព ត្រឹមតែជាកម្រិតជាតិប៉ុណ្ណោះ និងមិនអនុវត្តនៅ អ.វ.ត.ក ដែលអង្គបុរេជំនុំជម្រះបានយល់ឃើញថាជាតុលាការមួយដែលមានចរិតលក្ខណៈជា "តុលាការអន្តរជាតូបនីយកម្ម"[៦] នោះទេ និង គ. បទដ្ឋាននីតិវិធីដែលបានបង្កើតនៅកម្រិតអន្តរជាតិ មានករណីលើកលែងចំពោះ *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នៅពេលដែលការជំនុំជម្រះក្តីកាលពីមុនបានប្រព្រឹត្តទៅដោយមិនឯករាជ្យ ឬមិនអនាគតិ។ ការជំនុំជម្រះក្តីរបស់លោក អៀង សារី កាលពីមុន ស្ថិតនៅក្នុងករណីលើកលែង[៧]។

៣. សារណាបន្ថែមនេះបង្ហាញពីបញ្ហានានាដូចខាងក្រោម:

ក. បញ្ហាថាតើអង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំនៅក្នុងការសម្រេចថាតើ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនអាច អនុវត្តបាន ឬយ៉ាងណា។

ខ. បញ្ហាថាតើអង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំនៅក្នុងការសម្រេចថាតើ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមិន អាចអនុវត្តបាន ឬយ៉ាងណា។

គ. បញ្ហាថាតើអង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំនៅក្នុងការពិចារណាអំពីបទដ្ឋាននីតិវិធីដែលបានបង្កើតនៅកម្រិតអន្តរជាតិ ឬយ៉ាងណា និង

ឃ. បញ្ហាថាតើការជំនុំជម្រះក្តីឆ្នាំ ១៩៧៩ ត្រូវបានធ្វើឡើងស្របតាមបទដ្ឋាននៃការជំនុំជម្រះក្តីដោយភាពយុត្តិធម៌ជាមូលដ្ឋាន រួមទាំងក្របខ័ណ្ឌច្បាប់ដែលបានធ្វើជាមូលដ្ឋាន ឬយ៉ាងណា។

## II. **ខន្តីករណ៍**

---

[៥] សាលដីកា អបជ កថាខណ្ឌ ១១៩ ដល់ ១២៤។

[៦] ដូចខាងលើ កថាខណ្ឌ ១២៧ ដល់ ១៣១។

[៧] ដូចខាងលើ កថាខណ្ឌ ១៣២ ដល់ ១៧៥។

## ក. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជារារាំងការចោទប្រកាន់លោក អៀង សារី នាពេលបច្ចុប្បន្ន

៤. អង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំនៅក្នុងការវិភាគពី ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងនៅក្នុងការសម្រេចថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនរារាំងការចោទប្រកាន់លោក អៀង សារី នាពេលបច្ចុប្បន្ននេះទេ។ អង្គបុរេជំនុំជម្រះបានលើកឡើងថា ការ ប្រើពាក្យ "ការសម្រេចឱ្យរួចខ្លួនជាស្ថាពរ" នៅក្នុងមាត្រា ១២[៨] មានន័យថា បទប្បញ្ញត្តិនេះមិនអាច អនុវត្តនៅក្នុងករណីរបស់លោក អៀង សារី បានទេ ពីព្រោះលោក អៀង សារី មិនត្រូវបានសម្រេច ឱ្យរួចខ្លួនជាស្ថាពរនៅឆ្នាំ ១៩៧៩ នោះទេ ប៉ុន្តែត្រូវបានផ្តន្ទាទោសរួចហើយ[៩]។ អង្គបុរេជំនុំជម្រះបាន យល់ឃើញថា អត្ថន័យធម្មតានៃ "ការសម្រេចឱ្យរួចខ្លួនជាស្ថាពរ" នៅក្នុងមាត្រា១២ មិនបានបង្កឱ្យមានភាពមិនស៊ីសង្វាក់គ្នា ជាមួយនឹងផ្នែកដែលនៅសល់ផ្សេងទៀតរបស់ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានោះទេ និងថា នៅពេលដែលគ្មានភាពមិនសមហេតុសមផល និងភាពមិនស៊ីសង្វាក់គ្នាទេនោះ អង្គបុរេជំនុំជម្រះត្រូវប្រកាន់យកអត្ថន័យធម្មតានៃមាត្រា ១២[១០]។

៥. ការបកស្រាយនេះមានវិការៈ។ ជាដំបូង មាត្រា ៧ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា បណ្តឹងអាជ្ញាត្រូវផុតរលត់ក្នុង ករណី*អាជ្ញាអស់ជំនុំ*[១១]។ *អាជ្ញាអស់ជំនុំ* មានន័យថា:

> [ពាក្យឡាតាំង "រឿងដែលត្រូវបានវិនិច្ឆ័យ"] ១. បញ្ហាដែលត្រូវបានដោះស្រាយជាស្ថាពរ តាមរយៈសេចក្តីសម្រេចរបស់តុលាការ ២. ការការពារជាវិជ្ជមានដែលរារាំងភាគីដដែល មិនឱ្យធ្វើពាក្យបណ្តឹងទីពីរស្តីពីការទាមទារដដែល ឬការទាមទារផ្សេងទៀតដែលកើតចេញមកពីលទ្ធផលនៃស្វែងរកដំណោះស្រាយមួយ ឬច្រើន ទោះបីជាការទាមទារនោះអាចត្រូវបានត្រូវបានលើកឡើងនៅក្នុង

---

[៨] មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងថា "នៅក្នុងការអនុវត្តគោលការណ៍ *អាជ្ញាអស់ជំនុំ* ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ"។

[៩] សាលដីកា អបជ កថាខណ្ឌ ១២២ ដល់ ១២៤។

[១០] ដូចខាងលើ។

[១១] មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងថា "ការរលត់បណ្តឹងអាជ្ញា។ មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅគឺ:..... ៥. អាជ្ញាអស់ជំនុំ។ កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌ មិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់"។

ពាក្យបណ្ដឹងទីមួយ ប៉ុន្តែខ្លួនមិនបានធ្វើយ៉ាងនេះក៏ដោយ។ ធាតុផ្សំសំខាន់បីយ៉ាង គឺ (១) សេចក្ដីសម្រេចមុនលើបញ្ហានោះ (២) សាលក្រមស្ថាពរសម្រេចលើអង្គសេចក្ដី និង (៣) ភាពពាក់ព័ន្ធរបស់ភាគីដដែល ឬភាគីដែលមានចំណងទាក់ទងជាមួយនឹងភាគីដើមដំបូង...[១២]។

ករណីរបស់លោក អៀង សារី គឺករណី *អាជ្ញាអស់ជំនុំ*។ ការជំនុំជម្រះក្ដីបច្ចុប្បន្នជាប់ពាក់ព័ន្ធនឹងបញ្ហាដែលត្រូវបានដោះស្រាយជាស្ថាពរតាមរយៈសេចក្ដីសម្រេចរបស់តុលាការ ឆ្នាំ ១៩៧៩[១៣] រួចហើយ។ ដូចនេះ មាត្រា ៧ រារាំងការចោទប្រកាន់លោក អៀង សារី នាពេលបច្ចុប្បន្ននេះទេ។ ដូចដែលបានកត់សម្គាល់ដោយក្រុមអ្នកស្រាវជ្រាវផ្នែកច្បាប់ជនជាតិហូឡង់ André Klip និង Harmen van der Wilt "វិធានច្បាប់តម្រូវថា ប្រសិនបើរដ្ឋបានចាប់ផ្ដើមធ្វើការចោទប្រកាន់លើនរណាម្នាក់ក្នុងចំណោមពលរដ្ឋរបស់ខ្លួន រដ្ឋនោះនឹងគោរពលទ្ធផលនៃកិច្ចដំណើរការនីតិវិធី។ ហេតុដូច្នេះ សេចក្ដីសម្រេចរបស់តុលាការត្រូវតែគោរពតាម។ ប្រសិនបើ *អាជ្ញាអស់ជំនុំ* មិនត្រូវបានគេចាត់ទុកជាស្ថាពរទេ វានឹងធ្វើឱ្យធម្មានុរូបភាពរបស់រដ្ឋនោះធ្លាក់ចុះ"[១៤]។

៦. មាត្រា ១២ មិនកំណត់ន័យ *អាជ្ញាអស់ជំនុំ* សម្រាប់គោលបំណងនៃមាត្រា ៧ ឬដាក់កំហិតការអនុវត្តពាក្យនេះទេ។ ផ្ទុយទៅវិញ មាត្រា ១២ ធានាថា គោលការណ៍ *អាជ្ញាអស់ជំនុំ* ត្រូវបានចែងយ៉ាងទូលំទូលាយដើម្បីគ្របដណ្ដប់លើការសម្រេចឱ្យរួចខ្លួន និងស្ថានភាពដែលជនជាប់ចោទត្រូវបានចោទប្រកាន់ពីហេតុនៃអំពើដូចគ្នានឹងហេតុនៅក្នុងករណីកាលពីមុន ប៉ុន្តែត្រូវប្រើក្របខ័ណ្ឌគតិយុត្តិខុសគ្នា។ មិនមានការចាំបាច់ធ្វើការបកស្រាយមាត្រា ១២ នៅក្នុងករណីនេះទេ ពីព្រោះការជំនុំជម្រះក្ដីលោក អៀង សារី នាពេលបច្ចុប្បន្នត្រូវបានហាមឃាត់ ផ្អែកតាមគោលការណ៍ទូលំទូលាយនៅក្នុងមាត្រា ៧។

---

[១២] វចនានុក្រម BLACK'S LAW 1312 (បោះពុម្ពលើកទី ៧ ឆ្នាំ ១៩៩៩)។

[១៣] សម្រាប់ការពិភាក្សាអំពីភាពស្ថាពរនៃសាលក្រម ឆ្នាំ ១៩៧៩ *សូមមើល* សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារ D427/1/23 កថាខណ្ឌ ៣៥។

[១៤] រឿងក្ដី André Klip & Harmen van der Wilt របាយការណ៍ច្បាប់ព្រហ្មទណ្ឌអន្តរជាតិស្ដីពីគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* INTERNATIONALE DE DROIT PENAL 1091, 1094 (2002) ("Klip & van der Wilt")។

៧. ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការចាំបាច់ក្នុងការអនុវត្តមាត្រា ១២ រួមជាមួយមាត្រា ៧ នោះ មាត្រា ១២ ត្រូវយកមកធ្វើការបកស្រាយដើម្បីអនុវត្តចំពោះជនទាំងឡាយណាដែលត្រូវបានផ្តន្ទាទោសជាស្ថាពរ ក៏ដូចជាជនទាំងឡាយណាដែលត្រូវបានសម្រេចឲ្យរួចខ្លួនជាស្ថាពរផងដែរ។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការអានមាត្រា ១២ ដើម្បីអនុវត្តចំពោះទណ្ឌិតផង នឹងមិនស៊ីសង្វាក់គ្នាជាមួយនឹងផ្នែកផ្សេងទៀតនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា នោះឡើយ[១៥]។ នេះដោយសារតែបទប្បញ្ញត្តិមួយចំនួននៃ អនុញ្ញាតឲ្យបើកដំណើរការនីតិវិធីឡើងវិញ នៅក្នុងករណីដែលមានការផ្តន្ទាទោសរួចហើយដើម្បី ពិនិត្យដំណើរការនីតិវិធីឡើងវិញ ក្នុងករណីមានការផ្តន្ទាទោសរួចហើយ និងដើម្បីអនុញ្ញាតឲ្យមានការកាត់សេចក្តីជាថ្មីឡើងវិញ ចំពោះការជំនុំជម្រះក្តីនានាដែលត្រូវបានធ្វើឡើងដោយ*កំបាំងមុខ*។ អង្គបុរេជំនុំជម្រះជឿថា ការអនុវត្តមាត្រា ១២ នៅក្នុងស្ថានភាពទាំងអស់នេះនឹង "នាំឲ្យមានការបោះបង់ចោល" នូវលទ្ធភាពនៃការបើកឲ្យមានដំណើរការនីតិវិធីឡើងវិញ[១៦]។

៨. ការវិភាគរបស់អង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំ។ គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មានចេតនាការពារជនជាប់ចោទ។ វាជាសិទ្ធិដែលជនជាប់ចោទអាចយកមកប្រើជាសំអាងសម្រាប់ការពារខ្លួន។ វាមិនដើរតួនាទីធ្វើឲ្យខូចប្រយោជន៍របស់ជនជាប់ចោទ ដោយការរារាំងមិនឲ្យគាត់គាត់មិនឲ្យបើកឲ្យសើរើរឿងក្តីរបស់គាត់ឡើងវិញ ដែលគាត់ប្រាថ្នាចង់ប្រើប្រាស់ការការពារផ្សេងទៀតដែលចែងដោយ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានោះឡើយ។ ដូចនេះ វាមិនមែនមិនស៊ីសង្វាក់គ្នាជាមួយនឹងបទប្បញ្ញត្តិផ្សេងទៀតនៃ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលដើរតួនាទីការពារផលប្រយោជន៍របស់ជនជាប់ចោទនោះទេ។ André Klip និង Harmen van der Wilt ដែលបានធ្វើការវិភាគច្បាប់ហូឡង់ ស្តីពី*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* បានធ្វើការពន្យល់ថា: "តាមទ្រឹស្តី ការសើរើឡើងវិញ... មិនទុកថាពាក់ព័ន្ធនឹង *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នោះទេ។ ការផ្តួចផ្តើមឲ្យមានការសើរើឡើងវិញជាគំនិតរបស់ទណ្ឌិត ហើយស្ថានភាពរបស់គាត់ មិនអាចកាន់តែធ្ងន់ធ្ងរដោយសារនីតិវិធីនេះទេ"[១៧]។

---

[១៥] សាលដីកា អបជ កថាខណ្ឌ ១២៣។

[១៦] ដូចខាងលើ។

[១៧] Klip & van der Wilt ត្រង់ទំព័រ ១០៩៧។

៩. ការកំណត់មាត្រា ១២ ត្រឹមតែជនទាំងឡាយណាដែលត្រូវបានសម្រេចឱ្យរួចខ្លួនជាស្ថាពរ នឹងនាំឱ្យមានលទ្ធផលដែលមិនសមហេតុផល។ ពុំមានមូលដ្ឋានសមស្របសម្រាប់ធ្វើការបែងចែករវាងទណ្ឌិតដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយ និងជនដែលត្រូវបានសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយនោះទេ ជាពិសេសនៅពេលធ្វើការពិចារណាពីគោលបំណងនៃគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែលត្រូវអនុវត្តដូចគ្នាចំពោះករណីទាំងពីរ។ គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* "ត្រូវបានចាត់ថ្នាក់ជាអនុសាធ្យនៃការទទួលស្គាល់អានុភាព*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នៃសាលក្រមផ្សេងទៀត ដែលមានបំណងការពារភាពស្ថាពរនៃសាលក្រម។ គំនិតនេះគឺថា នៅពេលដែលករណីមួយត្រូវបានសម្រេចរួចហើយ ករណីនេះមិនត្រូវបើកឱ្យដំណើរការឡើងវិញនោះទេ (ករណីត្រូវបានបញ្ចប់ factum praeteritum) ពីព្រោះទង្វើបែបនេះនឹងប៉ះពាល់ខ្លាំងដល់ការគោរពនីតិវិធីតុលាការ និងការគោរពតុលាការទូទៅ"[១៨]។ ពាក្យនេះត្រូវបានហៅថា "អានុភាពនីតិវិធី" នៃគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*[១៩]។ សេចក្តីត្រូវការសម្រាប់ អ.វ.ត.ក ក្នុងការដើរតួនាទីជាតុលាការគំរូសម្រាប់ប្រទេសកម្ពុជា[២០] តាមរយៈការប្រកាន់ខ្ជាប់នូវវិធានច្បាប់ និងគោលការណ៍នីត្យានុកូលភាព

---

[១៨] រឿងក្តី YASMIN Q. NAQVI ឧបសគ្គនៃការអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិ ៣០៧ ដល់៣០៨ (T.M.C. Asser Press 2010) ("NAQVI")។

[១៩] ដូចខាងលើ ត្រង់ ២៩២ ដល់ ២៩៣។

[២០] "អ.វ.ត.ក ត្រូវបានចាត់តាំងជាតុលាការគំរូសម្រាប់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌កម្ពុជា"។ អនុសាសន៍ ពាក់ព័ន្ធនឹងតម្លាភាពបន្ថែមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដែលបានលើកឡើងដោយ សមាជិកសង្គមស៊ីវិល និងសមាជិកសាព័ត៌មានកម្ពុជា ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ អាចបើកមើលបាននៅ http://www.cambodiatribunal.org/CTM/Recommendations%20Regarding%20Additional%20 Transparency.pdf?phpMyAdmin=8319ad34ce0db941ff04d8c788f6365e។ ថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានអះអាងជាថ្មីម្តងទៀតពីបញ្ហានេះ ដោយបានលើកឡើងថា អ.វ.ត.ក ធ្វើការងារដើម្បី "ជំរុញ និងគូសបញ្ជាក់ពីលក្ខណៈសំខាន់នៃការការពារឯករាជ្យភាព និងបូរណភាពតុលាការ" និង ថា អង្គជំនុំជម្រះសាលាដំបូងនឹងធានាថា កិច្ចដំណើរការនីតិវិធី "ត្រូវបានធ្វើឡើងយោងតាមបទដ្ឋានអន្តរជាតិ" សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង សារី ប្តឹងជំទាស់ចៅក្រម និល ណុន និងសំណើពាក់ព័ន្ធនានា ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ឯកសារ E5/3 កថាខណ្ឌ ១៤ ដល់ ១៥។

និងការបង្កើនការគោរពតុលាការ និងកិច្ចដំណើរការនីតិវិធីតុលាការ នឹងធ្វើឱ្យ អ.វ.ត.ក ត្រូវគោរព និង អនុវត្តគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*។

១០. គោលបំណងផ្សេងទៀតនៃគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* គឺដើម្បីចៀសវាងមិនឱ្យបុគ្គលណាម្នាក់ទទួលរងសម្ពាធផ្លូវចិត្ត សម្ពាធនៃការរំជួលចិត្ត សម្ពាធផ្លូវកាយ និងសម្ពាធផ្នែកប្រាក់កាស ដោយសារតែមានការផ្តន្ទាទោសពីបទព្រហ្មទណ្ឌចំនួនពីរដង។ គោលបំណងនេះ មិនគ្រាន់តែអនុវត្តតែនៅពេលដែលជនជាប់ចោទត្រូវបានសម្រេចឱ្យរួចខ្លួននោះទេ។ កង្វល់ និងសម្ពាធ ដែលបង្កឡើងដោយសារការចោទប្រកាន់ម្តងហើយម្តងទៀត ប៉ះពាល់ដល់ក្រុមគ្រួសារ សាក្សី និង ជនរងគ្រោះ និងទំនងជាកាន់តែមានភាពធ្ងន់ធ្ងរឡើងដោយសារតែការយកចិត្តទុកដាក់របស់សារព័ត៌មាន[២១]។ គោលបំណងនៃគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ទាំងអស់នេះ បង្ហាញថា វានឹងមិនសមហេតុផលទេក្នុងការដាក់កំហិតគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែលមានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ អាចការពារបានតែចំពោះតែអ្នកទាំងឡាយណាដែលត្រូវបានសម្រេចឱ្យរួចខ្លួនជាស្ថាពរ តែប៉ុណ្ណោះ។

### ខ. កតិកាសញ្ញា ICCPR រារាំងការចោទប្រកាន់លោក អៀង សារី នាពេលបច្ចុប្បន្ន

១១. អង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំនៅក្នុងការវិភាគបញ្ហាថាតើកតិកាសញ្ញា ICCPR រារាំងការចោទប្រកាន់លោក អៀង សារី នាពេលបច្ចុប្បន្ននេះដែរឬទេ និងនៅក្នុងការសន្និដ្ឋានថា កតិកាសញ្ញា ICCPR មិនរារាំងការចោទប្រកាន់នោះទេ។ អង្គបុរេជំនុំជម្រះបានធ្វើការវិភាគពីការអនុវត្តកតិកាសញ្ញា ICCPR នៅក្នុងលក្ខណៈ ដូចខាងក្រោម:

ក. ដំបូង អង្គបុរេជំនុំជម្រះបានយល់ឃើញថា គណៈកម្មាធិការសិទ្ធិមនុស្សបានលើកឡើងថា មាត្រា ១៤(៧) “មិនធានាចំពោះគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែ*

---

[២១] NAQVI ត្រង់ ៣០៧។

*មួយ* ទាក់ទងនឹងយុត្តាធិការជាតិរបស់រដ្ឋពីរ ឬច្រើននោះទេ" ប៉ុន្តែហាមឃាត់ចំពោះតែការកាត់ទោសពីរដង ទាក់ទងនឹងបទល្មើសដែលបានវិនិច្ឆ័យនៅក្នុងរដ្ឋណាមួយតែប៉ុណ្ណោះ[២២]។

ខ. បន្ទាប់មក អង្គបុរេជំនុំជម្រះបានយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *Tadić* របស់តុលាការ ICTY បានសង្កេតឃើញថា មាត្រា ១៤(៧) នៃកតិកាសញ្ញា ICCPR "មិនមានការទទួលស្គាល់ទូលំទូលាយថា ជាបទដ្ឋានដាច់ខាតនៃការអនុវត្តជាអន្តរប្រទេសនោះទេ"[២៣]។

គ. អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា បណ្តារដ្ឋអឺរ៉ុបត្រូវទទួលស្គាល់ជំហរដែលថា មាត្រា ១៤(៧) នៃកតិកាសញ្ញា ICCPR មិនអនុវត្តជាអន្តរប្រទេសនោះទេ ពីព្រោះ អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("ECHR") បានលើកឡើងយ៉ាងច្បាស់លាស់ថា គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* អនុវត្តចំពោះតែកិច្ចដំណើរការនីតិវិធីដែលស្ថិតនៅក្នុងរង្វង់ច្បាប់ជាតិតែប៉ុណ្ណោះ[២៤]។

ឃ. អង្គបុរេជំនុំជម្រះលើកឡើងថា ការមិនអនុវត្តមាត្រា ១៤(៧) ជាអន្តរប្រទេសអាចត្រូវបានពន្យល់យ៉ាងច្បាស់ថា រដ្ឋមួយមិនមានកាតព្វកិច្ចទទួលស្គាល់សាលក្រមបរទេសបានទេ លើកលែងតែរដ្ឋនោះបានយល់ព្រមទទួលស្គាល់[២៥]។

ង. អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញ "ថា វិសាលភាពនៃមាត្រា ១៤(៧) ត្រូវបានកម្រិតយ៉ាងតឹងរ៉ឹងបំផុត ដោយសារមាត្រានេះអនុវត្តចំពោះ "បទល្មើស" ដដែល មានន័យថា ចរិតលក្ខណៈគតិយុត្តដូចគ្នានៃអំពើទាំងនោះ ទោះបីជាការការពារជាអន្តរជាតិផ្តោតទៅលើ "ទង្វើ" របស់ជនជាប់ចោទ ដោយការពិចារណាទៅលើការអនុវត្តគោលការណ៍ *គ្មានការកាត់*

---

[២២] សាលដីកា អបជ កថាខណ្ឌ ១២៨ *quoting A.R.J. v. Australia,* CCPR/C/60/D/692/1996 ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៦.៤ (សេចក្តីបញ្ជាក់បន្ថែម)។

[២៣] រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Tadić,* IT-94-1-T សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីស្តីពីគោលការណ៍ *មិនមានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ កថាខណ្ឌ ១៩។

[២៤] សាលដីកា អបជ កថាខណ្ឌ ១២៨ រៀបរាប់ពីមាត្រា ៤(១) នៃពិធីសារលេខ ៧ ទៅនឹង ECHR។

[២៥] ដូចខាងលើ កថាខណ្ឌ ១២៩។

00700474



*ទោសពីរដងចំពោះបទល្មើសតែមួយ* ចំពោះការណ៍ដែលថា ដំណើរការនីតិវិធីអន្តរជាតិអាចមានចរិតលក្ខណៈគតិយុត្តិខុសពីដំណើរការនីតិវិធីនៅកម្រិតជាតិ”[២៦]។

---

[២៦] ការអង្កេតធ្វើឡើងដោយអង្គបុរេជំនុំជម្រះនេះ នឹងមិនត្រូវបានលើកឡើងនៅពេលនេះទេ ពីព្រោះអង្គបុរេជំនុំជម្រះមិនបានធ្វើការសម្រេចផ្អែកតាមការអង្កេតនេះទេ។ លើសពីនេះទៀត ការអង្កេតនេះមិនសំខាន់នោះទេនៅក្នុងស្ថានភាពបច្ចុប្បន្ន ពីព្រោះវាហាក់ដូចជាច្បាស់លាស់ណាស់ថា លោក អៀង សារី ត្រូវបានចោទប្រកាន់ពីបទល្មើសដូចគ្នានឹងការជាប់ពិរុទ្ធភាព នៅឆ្នាំ ១៩៧៩ ទោះបីជាមេធាវីការពារក្តីបានត្រៀមលក្ខណៈលើកឡើងនូវបញ្ហានេះនៅក្នុងទឡ្ហីករណ៍ផ្ទាល់មាត់នៅពេល សវនាការបឋមប្រសិនបើចាំបាច់។ បន្ថែមពីលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ នៅឆ្នាំ ១៩៧៩ លោក អៀង សារី ត្រូវបានគេរកឃើញថាមានពិរុទ្ធភាពចំពោះ៖

I. អនុវត្តផែនការសម្លាប់រង្គាលដោយមានខ្សែរយៈ ប្រព្រឹត្តទៅលើប្រជាជនគ្រប់ប្រភេទគ្រប់ស្រទាប់វណ្ណៈក្នុងសភាពសាហាវឃោរឃៅបំផុត បានសម្លាប់រង្គាល គ្មានរើសមុខថាជានាយទាហាន ឬជាពលទាហាននៃរបបចាស់ សម្លាប់រង្គាលនូវបញ្ញវន្តគ្រប់ជាន់ថ្នាក់ សម្លាប់រង្គាលទាំងមនុស្ស ទាំងចលនាដែលពួកវាយល់ថាប្រឆាំងនឹងពួកវា។

II. ការកាប់សម្លាប់អ្នកដឹកនាំសាសនា សាសនិកជន ការលុបបំបាត់សាសនា ការសម្លាប់រង្គាលជនជាតិភាគតិចដោយគ្មានការបែងចែករវាងអ្នកប្រឆាំង និងអ្នកមិនប្រឆាំងនោះទេ ដើម្បីសម្រេចគោលបំណងរំលាយសាសនា។ ការសម្លាប់រង្គាលជនបរទេស។

III. ការបណ្តេញប្រជាជនចេញពីរដ្ឋធានីភ្នំពេញ ពីទីក្រុង និងជនបទដែលទើបរំដោះនាំឱ្យមានការវិនាស ហិនហោចដល់មូលដ្ឋានគ្រួសារ មូលដ្ឋានសង្គម និងនាំឱ្យមានការសម្លាប់រង្គាលដល់ពួកមនុស្ស។

IV. ប្រមូលផ្តុំប្រជាជនឱ្យចូល “សហករណ៍” ដែលជាជំរំប្រមូលផ្តុំក្លែងភេទ គាបសង្កត់ប្រជាជនឱ្យធ្វើការ និងឱ្យរស់នៅក្នុងលក្ខណៈវិនាសអន្តរាយទាំងរូបកាយទាំងស្មារតី សម្លាប់ ឬស្លាប់យ៉ាងរង្គាល។

V. កាប់សម្លាប់កុមារ និងការបង្ខឹកខួរកុមារជំទង់ឱ្យទៅជាជនឃោរឃៅកាចសាហាវ លែងមានសារជាតិជាមនុស្ស។

VI. បំផ្លាញសម្ព័ន្ធសេដ្ឋកិច្ច បំផ្លាញខឿនវប្បធម៌ អប់រំ ខឿនសុខាភិបាល

VII. ក្រោយត្រូវកងកម្លាំងប្រដាប់អាវុធបរិសុទ្ធវាយរំលំ បន ប៉ុល ពត - អៀង សារី នៅតែរឹងរូសបន្តការ ប្រឆាំងនឹងបដិវត្តន៍ដោយប្រព្រឹត្តបទឧក្រិដ្ឋថ្មីៗទៀតក្នុងការកាប់សម្លាប់ អ្នកដែលប្រឆាំងនឹងពួកវា។ ក្នុងរយៈពេល ៤ ឆ្នាំដែលពួកវាប្លន់យកអំណាចដឹកនាំប្រទេស បន ប៉ុល ពត-អៀង សារី បានអនុវត្តវិធីសាស្ត្រយ៉ាងព្រៃផ្សៃបំផុតដើម្បីដាក់ទណ្ឌកម្ម និងសម្លាប់មនុស្ស។

*សូមមើល* សាលក្រមរបស់តុលាការបដិវត្តន៍របស់ប្រជាជនបដិវត្តន៍ ឯកសារ U.N. A/34/491 ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ ទំព័រ ៣ ដល់ ២១។

**សារណាបន្ថែមរបស់លោក អៀង សារី លើអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩**

**(គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ)**

ច. អង្គបុរេជំនុំជម្រះបានយល់ឃើញថា មាត្រា ១៤(៧) នៃកតិកាសញ្ញា ICCPR មិនអនុវត្ត នៅតុលាការអន្តរជាតិនានានោះទេ"[២៧] និង

ឆ. អង្គបុរេជំនុំជម្រះបានយោងលើការយល់ឃើញរបស់ខ្លួនថា អ.វ.ត.ក គឺជាតុលាការមួយដែលមានលក្ខណៈជាតុលការ"អន្តរជាតូបនីយកម្ម" និងបានសន្និដ្ឋានថា មាត្រា ១៤(៧) មិនអនុវត្ត នៅ អ.វ.ត.ក នោះទេ[២៨]។

១២. ការវិភាគនេះមានការភ័ន្តច្រឡំច្រើនអន្លើ។ ទីមួយ ស្ថានភាពបច្ចុប្បន្នមិនពាក់ព័ន្ធនឹងការអនុវត្ត មាត្រា ១៤(៧) ជាអន្តរប្រទេសនោះទេ។ ទីពីរ អ.វ.ត.ក មិនអាចប្រៀបធៀបជាមួយនឹងតុលាការ ICTY បានទេ។ ជាចុងក្រោយ ទោះបីជាស្ថានភាពបច្ចុប្បន្នអាចត្រូវបានពិចារណាថាជាបញ្ហានៃការ អនុវត្ត ជាអន្តរប្រទេសក៏ដោយ អង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំនៅក្នុងការសម្រេចថា កតិកាសញ្ញា ICCPR មិនយកមកអនុវត្តនោះទេ។

**១. នេះមិនមែនជាបញ្ហានៃការអនុវត្តជាអន្តរប្រទេសនោះទេ ទោះបីជា អ.វ.ត.ក ត្រូវបានពិចារណាឃើញថាជាតុលាការ ដែលមានចរិតលក្ខណៈជាតុលាការ "អន្តរជាតូបនីយកម្ម" ក៏ដោយ**

១៣. និយមន័យនៃពាក្យ "ជាអន្តរប្រទេស" របស់វចនានុក្រមធម្មតា គឺ "ការលាតសន្ធឹង ឬការទៅហួសពីព្រំដែនជាតិ"[២៩]។ នេះគឺជាអត្ថន័យនៃពាក្យនេះនៅក្នុងករណីដែលត្រូវបានអង្គបុរេជំនុំជម្រះយកធ្វើជាសំអាង[៣០]។ ការជំនុំជម្រះទោសលោក អៀង សារី កាលពីមុន នៅឆ្នាំ ១៩៧៩ ត្រូវបានធ្វើឡើងដោយតុលាការកម្ពុជានៅក្នុងប្រទេសកម្ពុជា។ លើសពីនេះទៀត អ.វ.ត.ក គឺជាតុលាការមួយ "ដែល

---

[២៧] សាលដីកា អបជ កថាខណ្ឌ ១៣០។

[២៨] ដូចខាងលើ កថាខណ្ឌ ១៣១។

[២៩] វចនានុក្រម Merriam Webster Online Dictionary, *អាចបើកមើលបាននៅ* http://www.merriam-webster.com/dictionary/transnational.។

[៣០] សូមមើលរឿងក្តី *See A.R.J.* តទល់នឹង *Australia, CCPRlC/60/D/69211996* ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៦.៤។ រឿងក្តី *A.P et al.* តទល់នឹង *Italy* ទំនាក់ទំនងលេខ ២០៤/១៩៨៦ ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ១៩៨៧ កថាខណ្ឌ ៧.៣។ ខណៈពេលដែលករណីទាំងអស់នេះមិនកំណត់និយមន័យនៃពាក្យ "ជាអន្តរប្រទេស" ករណី ទាំងអស់នេះបានធ្វើការពិចារណាលើបញ្ហាថាតើ មាត្រា ១៤(៧) នឹងយកមកអនុវត្តដែរឬទេ ដើម្បីឱ្យសាលក្រមដែល បានចេញនៅក្នុងយុត្តាធិការជាតិ នឹងត្រូវបានទទួលស្គាល់នៅក្នុងយុត្តាធិការជាតិទីពីរ។

ត្រូវបានបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់" នៃប្រទេសកម្ពុជា[៣១]។ ពុំមានបញ្ហានៃការហួសពីព្រំដែនជាតិនៅក្នុងស្ថានភាពបច្ចុប្បន្ននេះទេ។

១៤. ទោះបីជា អ.វ.ត.ក ត្រូវបានពិចារណាឃើញថា "តុលាការអន្តរជាតូបនីយកម្ម"[៣២] ដោយសារតែជំនួយផ្នែកបច្ចេកទេសអន្តរជាតិដែល អ.វ.ត.ក បានទទួល និងរចនាសម្ព័ន្ធពិសេសតែមួយរបស់ អ.វ.ត.ក ក៏ដោយ ចំណុចនេះមិនមានន័យថា អ.វ.ត.ក គឺជាតុលាការបរទេសរបស់រដ្ឋមួយផ្សេងទៀតនោះទេ។ ដូចនេះ ពុំមានការអនុវត្តគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* "ជាអន្តរប្រទេស" ពាក់ព័ន្ធឡើយ។ អ.វ.ត.ក មិនត្រូវបានស្នើសុំឱ្យទទួលស្គាល់សាលក្រមបរទេសនោះទេ តែត្រូវបានស្នើសុំឱ្យទទួលស្គាល់សាលក្រមកម្ពុជា។ ការពិចារណា "ជាអន្តរប្រទេស" ដែលបានរៀបរាប់ដោយអង្គបុរេជំនុំជម្រះ ពោលគឺ បញ្ហាថាតើកិច្ចដំណើរការនីតិវិធីបន្ទាប់កើតឡើងនៅក្នុងវង្វង់ច្បាប់ជាតិខុសៗគ្នាដែរឬទេ និងបញ្ហាថាតើសាលក្រមបរទេសតម្រូវឱ្យមានការទទួលស្គាល់មិនយកមកអនុវត្តនៅក្នុងបរិបទជាក់លាក់របស់ អ.វ.ត.ក ឬយ៉ាងណា។

១៥. អ.វ.ត.ក ទទួលបាននូវយុត្តាធិការ និងសមត្ថកិច្ច ដូចតុលាការកម្ពុជាផ្សេងទៀតដែរ - តាមរយៈច្បាប់ជាតិកម្ពុជា។ វាមិនមែនជាទំនាក់ទំនង "តាមខ្សែបណ្តោយ" ជាមួយនឹងតុលាការកម្ពុជាផ្សេងទៀតនោះទេ[៣៣] ទោះបីជាអង្គជំនុំជម្រះអាចត្រូវបានពិចារណាថាជា "អង្គជំនុំជម្រះវិសាមញ្ញ" ដោយមានភាពខុសប្លែកពីតុលាការកម្ពុជាផ្សេងទៀតក៏ដោយ។

---

[៣១] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២ ថ្មី។

[៣២] សម្រាប់ការពិភាក្សាស៊ីជម្រៅស្តីពីឋានៈរបស់ អ.វ.ត.ក ថាជា តុលាការជាតិ និងពាក្យថា "អន្តរជាតូបនីយកម្ម" មានន័យដូចម្តេច *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ ឯកសារ D427/1/6 កថាខណ្ឌ ៨ ដល់ ២០។ *សូមមើលផងដែរ* ការលើកឡើងថែមទៀតដែលមេធាវីការពារក្តីនឹងលើកបញ្ហានេះ នៅក្នុងសារណាបន្ថែមស្តីពីភាពអាចអនុវត្តច្បាប់ អន្តរជាតិបាន។

[៣៣] ពិចារណាលើទំនាក់ទំនងរបស់តុលាការ ICTY ជាមួយនឹងរដ្ឋផ្សេងទៀត ដែលត្រូវបានពន្យល់ដោយអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY នៅក្នុងរឿងក្តី *Blaškić:* "យ៉ាងជាក់ច្បាស់ ក្រោមមាត្រា ១ នៃច្បាប់លក្ខន្តិកៈ តុលាការអន្តរជាតិមានយុត្តាធិការរឿងក្តីព្រហ្មទណ្ឌតែលើ "រូបវន្តបុគ្គលដែលទទួលខុសត្រូវចំពោះការរំលោភបំពាន ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិដែលបានប្រព្រឹត្តនៅក្នុងទឹកដីអតីតយូហ្គោស្លាវីចាប់តាំងពី [ថ្ងៃទី ១ ខែ មករា] ឆ្នាំ ១៩៩១"។ តុលាការអន្តរជាតិអាចធ្វើការចោទប្រកាន់ និងកាត់ទោសជនទាំងអស់នោះបាន។ នេះគឺជាយុត្តាធិការបឋម។ ទោះបីជាយ៉ាងណាក៏ដោយ វាច្បាស់ណាស់ថា

១៦. ជាចុងក្រោយ នៅពេលធ្វើការពិចារណាពីលក្ខណៈរបស់ អ.វ.ត.ក និងបញ្ហាថាតើចំណុចនេះនឹងអនុញ្ញាតឱ្យមើលរំលងគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែរឬទេ អង្គជំនុំជម្រះសាលាដំបូងត្រូវចងចាំថា "ប្រសិនបើទស្សនាទាន "រដ្ឋ" បាត់បង់អត្ថន័យរបស់វា វានឹងមិនត្រូវធ្វើឱ្យមានការការពារបុគ្គលកាន់តែតិចទៅនោះទេ"[៣៤]។

## ២. អ.វ.ត.ក មិនអាចដូចគ្នាទៅនឹងតុលាការ ICTY ឬតុលាការ *មិនអចិន្ត្រៃយ៍*ដទៃទៀតឡើយ

---

ដើម្បីនាំយកជនដែលរស់នៅក្រោមយុត្តាធិការរបស់រដ្ឋអធិបតេយ្យ មកកាត់ទោស ដោយមិនផ្តល់ភ្នាក់ងារអនុវត្តផ្ទាល់ខ្លួន តុលាការអន្តរជាតិត្រូវផ្អែកលើកិច្ចសហការរបស់រដ្ឋនានា។ តុលាការអន្តរជាតិត្រូវងាកទៅរករដ្ឋនានា ប្រសិនបើចង់ធ្វើការស៊ើបអង្កេតបទល្មើស ប្រមូលភស្តុតាង កោះអញ្ជើញ សាក្សី និងធ្វើការចាប់ខ្លួនជនដែលត្រូវបានចោទប្រកាន់ និងប្រគល់ឱ្យតុលាការអន្តរជាតិដោយប្រសិទ្ធភាព។ អ្នកធ្វើសេចក្តីព្រាងច្បាប់លក្ខន្តិកៈបានធ្វើការពិចារណាចំណុចនេះតាមជាក់ស្តែង នៅក្នុងការកំណត់កាតព្វកិច្ចដល់គ្រប់រដ្ឋទាំងអស់ឱ្យជួយសហការ និងផ្តល់ជំនួយផ្លូវច្បាប់ដល់តុលាការអន្តរជាតិ។ កាតព្វកិច្ចនេះ មានចែងនៅក្នុងមាត្រា ២៩ និងត្រូវបានចែងឡើងវិញនៅក្នុងកថាខណ្ឌ ៤ នៃសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខ លេខ ៨២៧ (ឆ្នាំ ១៩៩៣)។ កម្លាំងចងភ្ជាប់កាតព្វកិច្ចនេះកើតចេញមកពីបទប្បញ្ញត្តិនៃជំពូក VII និងមាត្រា ២៥ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងពីសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខ ដែលត្រូវបានអនុម័តអនុលោមតាមបទប្បញ្ញត្តិទាំងអស់នោះ។ មូលដ្ឋានច្បាប់ ពិសេសនៃមាត្រា ២៩ ពន្យល់ពីរឿងរ៉ាវថ្មីប្លែក និងអំណាចពិសេសតែមួយគត់ដែលបានផ្តល់ឱ្យតុលាការអន្តរជាតិ ក្នុងការចេញការបង្គាប់បញ្ជានានាដល់រដ្ឋអធិបតេយ្យនានា (ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាបញ្ហាគោលការណ៍ រដ្ឋនានាមិនអាចត្រូវបាន "បង្គាប់បញ្ជា" ដោយរដ្ឋផ្សេងទៀត ឬដោយអង្គភាពអន្តរជាតិណាឡើយ)។ លើសពីនេះទៀត កាតព្វកិច្ចដែលបានកំណត់-នៅក្នុងអត្ថន័យច្បាស់លាស់បំផុត- នៅក្នុងមាត្រា ២៩ គឺជាកាតព្វកិច្ចដែលជាភារកិច្ច លើគ្រប់រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិប្រៀបធៀបនឹងរាល់រដ្ឋជាសមាជិកផ្សេងទៀត។ ក្រុមប្រឹក្សា សន្តិសុខ ដែលជាអង្គភាពដែលរ៉ាប់រងការទទួលខុសត្រូវបឋមសម្រាប់ការថែទាំសន្តិភាព និងសន្តិសុខអន្តរជាតិ បានចូលរួមយ៉ាងឱឡារិកជាមួយគ្រប់រដ្ឋជាសមាជិកក្នុងការអនុវត្តតាមការបង្គាប់បញ្ជា និងសំណើរបស់តុលាការអន្តរជាតិ។ លក្ខណៈ និងខ្លឹមសារនៃកាតព្វកិច្ចនេះ ក៏ដូចជាប្រភពដែលវាកើតចេញមកធ្វើឱ្យច្បាស់លាស់ថា មាត្រា ២៩ មិនបង្កើតបាន នូវទំនាក់ទំនងទ្វេរភាគីនោះទេ។ មាត្រា ២៩ ដាក់កាតព្វកិច្ចលើរដ្ឋជាសមាជិកនានាទៅលើសមាជិកទាំងអស់ផ្សេងទៀត ឬហៅម្យ៉ាងទៀតថា "កាតព្វកិច្ចដែលអនុវត្តចំពោះគ្រប់រដ្ឋ *erga omnes partes*"។ តាមរយៈភស្តុតាងដូចគ្នា មាត្រា ២៩ អះអាង ពីផលប្រយោជន៍សហគមន៍នៅក្នុងការប្រតិបត្តិមាត្រានេះ។ និយាយម្យ៉ាងទៀត គ្រប់រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិមានផលប្រយោជន៍ផ្លូវច្បាប់នៅក្នុងការបំពេញកាតព្វកិច្ចដែលបានកំណត់នៅក្នុងមាត្រា ២៩..."។ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Blaškić*, IT-95-14-AR108*ស្ទួន* សាលក្រមលើសំណើសុំរបស់សាធារណៈរដ្ឋក្រូអាតសុំពិនិត្យ មើលឡើងវិញនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៧, ចុះ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៧ កថាខណ្ឌ ២៦។ *សូមមើលផងដែរ* កថាខណ្ឌ ២៧ ដល់ ៣១។

[៣៤] Klip & van der Wilt. ត្រង់ទំព័រ ១១៣៥។

១៧. អង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំនៅក្នុងការប្រៀបប្រដូច អ.វ.ត.ក ទៅនឹងតុលាការ ICTY និងតុលាការ *មិនអចិន្ត្រៃយ៍*ដទៃទៀត។ ទោះបីជាអាចមានសញ្ញាណបង្ហាញនូវការប្រើពាក្យថា "មានលក្ខណៈអន្តរជាតិ" យ៉ាងណាក៏ដោយ ក៏ អ.វ.ត.ក ពុំមែនជាតុលាការអន្តរជាតិឡើយ[៣៥]។ តុលាការអន្តរជាតិមិនអាចត្រូវចងកាតព្វកិច្ចឱ្យអនុវត្តមាត្រា ១៤ នៃកតិកាសញ្ញា ICCPR ឡើយ ប៉ុន្តែ អ.វ.ត.ក ត្រូវបានផ្ដល់អំណាចឱ្យអនុវត្តបែបនេះ ដោយរដ្ឋធម្មនុញ្ញកម្ពុជា[៣៦] កិច្ចព្រមព្រៀង[៣៧] និងច្បាប់ស្ដីពីការ បង្កើត អ.វ.ត.ក[៣៨]។

១៨. ជាការគួរឱ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់អំពីភាពខុសគ្នា រវាងការអនុវត្តរបស់អង្គបុរេជំនុំជម្រះទៅ លើមាត្រា ១៤(៧) នៃកតិកាញ្ញា ICCPR និងមាត្រា ១៥។ នៅពេលពិចារណាថាតើគោលការណ៍នីត្យានុកូលភាពត្រូវយកមកអនុវត្តនៅ អ.វ.ត.ក គឺជាគោលការណ៍ដែលមានចែងនៅក្នុងមាត្រា ១៥ ឬយ៉ាងណានោះ អង្គបុរេជំនុំជម្រះបញ្ជាក់ថា "ដោយយោងយ៉ាងច្បាស់លាស់ [របស់ច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក] ទៅលើមាត្រា ១៥ នៃអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ចំពោះករណីឧក្រិដ្ឋកម្មអន្តរជាតិ គឺគ្មានអ្វីគួរឱ្យសង្ស័យនោះឡើយដែលថាគោលការណ៍នីត្យានុកូលភាពដែលមានចែងក្នុងច្បាប់ អ.វ.ត.ក គឺជាគោលការណ៍នីត្យានុកូលភាព

---

[៣៥] សូម្បីតែកិច្ចព្រមព្រៀង (ដែលមានលក្ខណៈ "អន្តរជាតិ" បំផុតក្នុងចំណោមលិខិតុបករណ៍ជាមូលដ្ឋានរបស់ អ.វ.ត.ក គ្រាន់តែមានអានុភាពគតិយុត្តិប៉ុណ្ណោះ ពីព្រោះកិច្ចព្រមព្រៀងនេះត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ជាតិប្រទេសកម្ពុជា ពុំមែនដោយសារតែកិច្ចព្រមព្រៀងនេះត្រូវបានប្រកាសឱ្យប្រើដោយក្រុមប្រឹក្សាសន្តិសុខឡើយ (ដូចក្នុងករណីតុលាការមិនអចិន្ត្រៃយ៍នានា) ឬមានអានុភាពគតិយុត្តិនៃសន្ធិសញ្ញា (ដូចលក្ខន្តិកៈរបស់តុលាការ ICC)។

[៣៦] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ១៩៩៩ មាត្រា ៣១។

[៣៧] មាត្រា ១២(២) នៃកិច្ចព្រមព្រៀងចែងថា "អង្គជំនុំជម្រះវិសាមញ្ញ ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុ សញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ" (សេចក្ដីបញ្ជាក់បន្ថែម)។ សូមមើល ផងដែរ មាត្រា ១៣(១) ដែលចែងថា "សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការ ជំនុំជម្រះក្ដី"។

[៣៨] មាត្រា ៣៣ថ្មី នៃច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក ចែងថា "អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្រប តាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ដូចដែលបាន ចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋនិងនយោបាយ"។

អន្តរជាតិ..."[៣៩]។ ប៉ុន្តែ អង្គបុរេជំនុំជម្រះពុំបានពិចារណាថា អង្គបុរេជំនុំជម្រះខ្លួនឯងផ្ទាល់មានកាតព្វកិច្ចអនុវត្តមាត្រា ១៤(៧) ដូចមាត្រា ១៥ ទោះបីជាច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ផ្ដល់អំណាចឲ្យយកវាមកអនុវត្តយ៉ាងណាក៏ដោយ។

១៩. ការយោងរបស់អង្គបុរេជំនុំជម្រះទៅលើសេចក្ដីសម្រេច អំពីគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្ដី *Tadić* គឺមិនត្រឹមត្រូវឡើយនៅក្នុងរឿងក្ដីនេះ។ អង្គជំនុំជម្រះសាលាដំបូងលើរឿងក្ដី *Tadić* ពុំបានកំណត់ថា កតិកាសញ្ញា ICCPR មិនអាចអនុវត្តបាននោះឡើយ។ អង្គជំនុំជម្រះនេះគ្រាន់តែកត់សម្គាល់ថា "បទប្បញ្ញត្តិត្រូវបានអនុវត្តជាទូទៅដើម្បីគ្របដណ្ដប់តែទៅលើការចោទប្រកាន់ពីរដងប៉ុណ្ណោះនៅក្នុងរដ្ឋតែមួយ..."[៤០]។ អង្គជំនុំជម្រះនេះពុំចាំបាច់កំណត់ ថាតើកតិកាសញ្ញា ICCPR នឹងរារាំងដល់ការចោទប្រកាន់ ឬយ៉ាងណានោះឡើយ ពីព្រោះអង្គជំនុំជម្រះនេះបានរកឃើញរួចហើយថា ពុំមានការជំនុំជម្រះទោសពីមុនឡើយ[៤១] ហើយដូចដែលអង្គជំនុំជម្រះនេះបានកត់សម្គាល់ កតិកាសញ្ញា ICCPR "អនុវត្តតែទៅលើរឿងក្ដីទាំងឡាយណាដែលជនជាប់ចោទត្រូវបានជំនុំជម្រះទោសរួចហើយប៉ុណ្ណោះ"[៤២]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះនេះកត់សម្គាល់ថា អនុលោមតាមលក្ខន្តិកៈតុលាការ ICTY ប្រសិនបើប្រទេសអាល្លឺម៉ង់ប៉ុនប៉ងធ្វើការចោទប្រកាន់ បន្ទាប់ពីតុលាការ ICTY បានធ្វើការកាត់ទោសលើជនជាប់ចោទរួចហើយនោះ ប្រការនេះពិតជានឹងលើកឡើងនូវបញ្ហាអំពីគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ..."[៤៣]។

### ៣. ទោះបីស្ថានភាពបច្ចុប្បន្នអាចត្រូវបានពិចារណាថាពាក់ព័ន្ធនឹងបញ្ហានៃការអនុវត្តជាអន្តរប្រទេសក៏ដោយ ក៏អង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំក្នុងការសម្រេចថា កតិកាសញ្ញា

---

[៣៩] សាលដីការបស់ អ.ប.ជ កថាខណ្ឌ ២១៣ (សេចក្ដីបញ្ជាក់បន្ថែម)។

[៤០] រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Tadić*, IT-94-1-T សេចក្ដីសម្រេចលើញត្តិរបស់មេធាវីការពារក្ដីស្ដីអំពីគោលការណ៍ គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ កថាខណ្ឌ ១៩។

[៤១] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១០-១២។

[៤២] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២០។

[៤៣] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១៣។

## ICCPR ពុំយកមកអនុវត្តបានឡើយ

២០. ទោះបីជាស្ថានភាពបច្ចុប្បន្នអាចត្រូវបានពិចារណាថា "មានលក្ខណៈអន្តរប្រទេស" ក៏ដោយ ក៏អង្គបុរេជំនុំជម្រះគួរតែផ្តោតលើការសម្រេចថា កតិកាសញ្ញា ICCPR ពុំយកមកអនុវត្តបានឡើយនៅក្នុងស្ថានភាពបែបនេះ។ អង្គបុរេជំនុំជម្រះផ្អែកទៅលើអង្គហេតុដែលថាគណៈកម្មាធិការសិទ្ធិមនុស្សបានលើកឡើងថា មាត្រា ១៤(៧) "មិនធានាចំពោះគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ ទាក់ទិននឹងយុត្តាធិការជាតិរបស់រដ្ឋពីរ ឬច្រើននោះទេ"[៤៤]។ ទោះបីជាយ៉ាងណាក៏ដោយ ពុំមានបទប្បញ្ញត្តិនៅក្នុងកតិកាសញ្ញា ICCPR ដែលផ្តល់សិទ្ធិជាផ្លូវការឲ្យគណៈកម្មាធិការសិទ្ធិមនុស្សធ្វើការបកស្រាយកតិកាសញ្ញា ICCPR ឡើយ។ ការបកស្រាយរបស់គណៈកម្មាធិការសិទ្ធិមនុស្សមិនចងកាតព្វកិច្ចឡើយ "ទោះបីជាយូរៗម្តងគណៈកម្មាធិការសិទ្ធិមនុស្សអាចលើកឡើងនូវទស្សនខុសគ្នាយ៉ាងណាក៏ដោយ"[៤៥]។

២១. វាមិនមានលក្ខណៈច្បាស់លាស់ទាល់តែសោះ ឬវាមិនត្រូវបានគេទទួលស្គាល់ជាសកលឡើយថា *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែលមានចែងនៅក្នុងមាត្រា ១៤(៧) នៃកតិកាសញ្ញា ICCPR អនុវត្តតែនៅក្នុងរដ្ឋ និងពុំមានអានុភាពជាអន្តរប្រទេសឡើយ។ សមាគមអន្តរជាតិស្តីពីច្បាប់ព្រហ្មទណ្ឌ[៤៦] បានអនុម័តសេចក្តីសម្រេចមួយដែលបញ្ជាក់ថា "គោលការណ៍គ្មាន

---

[៤៤] សាលដីការបស់ អ.ប.ជ កថាខណ្ឌ ១២៨។

[៤៥] Shiyan Sun, *The Understanding and Interpretation of the ICCPR in the Context of China's Possible Ratification*, 6 CHINESE J. INT'L L. 17, 23 (2007) ។ អត្ថបទបញ្ជាក់ថា "គោលជំហរដ៏ច្បាស់លាស់មួយដែលគណៈកម្មាធិការប្រកាន់យកទាក់ទិននឹងបញ្ហានេះ គឺការបញ្ជាក់ដែលបង្កជាបញ្ហានៅសេចក្តីអត្ថាធិប្បាយទូទៅលេខ ២៤ ថា "តួនាទីរបស់គណៈកម្មាធិការអនុលោមតាមកតិកាសញ្ញា ក្រោមមាត្រា ៤០ ឬពិធីសារតាមចិត្តជ្រើសរើស ចាំបាច់តម្រូវឲ្យមានការបកស្រាយបទប្បញ្ញត្តិនៃកតិកាសញ្ញា និងការអភិវឌ្ឍនៃយុត្តិសាស្ត្រ" ទោះបីជាសេចក្តីអត្ថាធិប្បាយទូទៅនោះ ពុំមានអានុភាពចងកាតព្វកិច្ចគតិយុត្តិក៏ដោយ"។ ដូចដើងទំព័រខាងលើ។

[៤៦] សមាគមអន្តរជាតិនៃច្បាប់ព្រហ្មទណ្ឌត្រូវបានបង្កើតឡើងក្នុងទីក្រុងប៉ារីស ឆ្នាំ១៩២៤។ សមាគមនេះគឺជាអ្នកបន្តវេន ពីសហជីពអន្តរជាតិនៃច្បាប់ព្រហ្មទណ្ឌ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៨៨៩ នៅក្នុងទីក្រុងវីយ៉ែន។ វាគឺជាសមាគមចំណាស់ជាងគេបំផុតនៃអ្នកជំនាញនៅក្នុងច្បាប់ព្រហ្មទណ្ឌ និងជាសមាគមវិទ្យាសាស្ត្រដ៏ចំណាស់ជាងគេបំផុតមួយក្នុង ចំណោមសមាគមវិទ្យាសាស្ត្រដ៏ចំណាស់ជាងគេបំផុតនានានៅក្នុងពិភពលោក។ សូមមើលគេហទំព័ររបស់សមាគមអន្តរជាតិនៃច្បាប់ព្រហ្មទណ្ឌ ដែលអាចរកមើលបាននៅគេហទំព័រ http://www.penal.org/?page=mainaidp&id_rubrique=13&lang=fr។

ការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ គួរតែត្រូវបានចាត់ទុកថា ជាសិទ្ធិមនុស្សដែលអាចអនុវត្ត ផងដែរនៅកម្រិតអន្តរជាតិ ឬអន្តរប្រទេស”[៤៧]។

២២. គណៈកម្មការពិសេសសម្រាប់បទឧក្រិដ្ឋធ្ងន់ធ្ងរ នៅក្នុងប្រទេសទីម័រខាងកើតយល់ឃើញថា *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* គឺអាចអនុវត្តបាននៅក្នុងប្រទេសទីម័រខាងកើត ដោយសារតែបទបញ្ញារដ្ឋបាលអន្តរកាលរបស់អង្គការសហប្រជាជាតិ ក្នុងប្រទេសទីម័រខាងកើត (UNTAET) ដែលបង្កើតគណៈកម្មាការពិសេស និងដោយសារវាមានចែងនៅក្នុងមាត្រា ១៤(៧) នៃកតិកាសញ្ញា ICCPR ដែលមានអានុភាពផ្នែកច្បាប់នៅក្នុងប្រទេសទីម័រខាងកើត[៤៨]។ គណៈកម្មាការពិសេសនេះបាន សម្រេចថា គោលការណ៍នេះពុំបានរារាំងការចោទប្រកាន់ជនជាប់ចោទ ដែលត្រូវបានចាប់ខ្លួននៅក្នុង ប្រទេសឥណ្ឌូនេស៊ីឡើយ មិនមែនដោយសារតែគោលការណ៍នេះពុំមានការអនុវត្តជាអន្តរប្រទេសនោះទេ ប៉ុន្តែដោយសារតែគណៈកម្មាការនេះយល់ឃើញថា គោលការណ៍នេះមិនអាចអនុវត្តបាននៅដំណាក់កាលនៃដីកាបង្គាប់ឲ្យនាំខ្លួននៃដំណើរការនីតិវិធី[៤៩]។

២៣. ប្រទេសហូឡង់មានមន្ទិលទៅលើមាត្រា ១៤(៧) នៃកតិកាសញ្ញា ICCPR ពីព្រោះ “រដ្ឋាភិបាលហូឡង់ <u>មានមន្ទិលថាតើ មាត្រា ១៤ កថាខណ្ឌ ៧ នឹងមានវិសាលភាពតែទៅលើការអនុវត្តនៅកម្រិតជាតិប៉ុណ្ណោះ</u> ឬក៏ទៅលើការអនុវត្តកម្រិតអន្តរជាតិផងដែរនៃគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ។ នៅក្នុងករណីដែលវាមានវិសាលភាពទៅលើការអនុវត្តនៅកម្រិតអន្តរជាតិនៃគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ តុលាការ [ប្រទេសហូឡង់] នឹងទំនងជាត្រូវបានតម្រូវឲ្យកាត់បន្ថយទោសដែលបានជាប់នៅក្រៅប្រទេស ក្នុងករណីដែលទោសមិនត្រូវបានអនុវត្តទាំងស្រុងនៅឡើយ ជាលក្ខខណ្ឌតម្រូវមួយដែល [ច្បាប់ព្រហ្មទណ្ឌប្រទេសហូឡង់] មិនបាន

---

[៤៧] សេចក្តីសម្រេច ផ្នែក IV B.4 ដែលត្រូវបានអនុម័តដោយសមាជអន្តរជាតិនៃច្បាប់ព្រហ្មទណ្ឌ អាចរកមើលបាននៅ គេហទំព័រ http://www.penal.org/IMG/pdf/NEP21anglais.pdf ។

[៤៨] រឿងក្តីអគ្គរដ្ឋអាជ្ញារងសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ទល់នឹង *Wiranto និងអ្នកផ្សេងទៀត សំណុំរឿងលេខ* 05/2003, សេចក្តីសម្រេចស្តីពីភាពអាចអនុវត្តបាននៃគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ នៅដំណាក់កាលដីកាបង្គាប់ឲ្យនាំខ្លួននៃដំណើរការនីតិវិធី ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ៥-១៧។

[៤៩] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១៨-៣៤។

បញ្ជាក់”[៥០]។

២៤. អង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំបន្ថែមទៀតក្នុងការធ្វើសេចក្តីសន្និដ្ឋានថា បណ្តាប្រទេសអឺរ៉ុបប្រកាន់ជំហរថាគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនមែនជាបទដ្ឋានដាច់ខាត (mandatory norm) នៃការអនុវត្តជាអន្តរប្រទេសនោះទេ ដោយផ្អែកលើមូលដ្ឋានថា មាត្រា ៤ នៃពិធីសារលេខ៧ ដាក់ទៅក្នុងកតិកាសញ្ញាទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្សបញ្ជាក់ថា គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* អនុវត្តចំពោះតែដំណើរការនីតិវិធីនៅក្នុងរង្វង់ច្បាប់ជាតិតែប៉ុណ្ណោះ[៥១]។ កតិកាសញ្ញាទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្សពុំបានបញ្ជាក់ថា គោលការណ៍នេះមិនអាចត្រូវបានយកមកអនុវត្តយ៉ាងទូលំទូលាយឡើយ[៥២]។ លើសពីនេះទៀត ការទទួលស្គាល់គោលការណ៍ដូចដែលមានចែងនៅក្នុងកតិកាសញ្ញាទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ពុំបានរារាំងការទទួលស្គាល់គោលការណ៍ដ៏ទូលាយជាង ដែលមានចែងនៅក្នុងលិខិតុបករណ៍ដទៃទៀតនោះឡើយ។ ប្រការនេះបង្ហាញឱ្យឃើញច្បាស់ពីការពិតដែលថា បណ្តារដ្ឋដែលជាសមាជិកមួយចំនួននៃសហគមន៍អឺរ៉ុបពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង Schengen ដែលហាមឃាត់ការចោទប្រកាន់ពីរដ្ឋសមាជិកមួយ ដោយមានករណីលើកលែងមួយចំនួន ប្រសិនបើមានការជំនុំជម្រះទោសរួចហើយចំពោះអំពើដដែលពីរដ្ឋសមាជិកមួយទៀត[៥៣]។ លើសពីនេះទៀត នៅអឺរ៉ុប ៖

---

[៥០] Klip & van der Wilt ត្រង់ទំព័រ ១១០១ (សេចក្តីបញ្ជាក់បន្ថែម)។

[៥១] សាលដីការបស់ អ.ប.ជ កថាខណ្ឌ ១២៨។

[៥២] មាត្រា ៤ នៃពិធីសារលេខ ៧ នៃកតិកាសញ្ញាទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្សចែងថា ៖ “១. គ្មានជនណាម្នាក់ ត្រូវប្រឈមមុននឹងការជំនុំជម្រះទោស ឬផ្តន្ទាទោសម្តងទៀតនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ រដ្ឋដដែល ចំពោះបទល្មើសដែលជននោះត្រូវបានសម្រេចឱ្យរួចផុតពីការចោទប្រកាន់ ឬត្រូវបានផ្តន្ទាទោសជាស្ថាពររួច ហើយ ស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនោះបានឡើយ។ ២. បទប្បញ្ញត្តិនៅក្នុងកថាខណ្ឌពីខាងមុខនេះមិន ត្រូវរារាំងដល់ការបើកសំណុំរឿងឡើងវិញ ស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋដែលពាក់ព័ន្ធឡើយ ប្រសិនបើ មានភ័ស្តុតាងនៃអង្គហេតុថ្មី ឬអង្គហេតុដែលត្រូវបានរកឃើញថ្មីៗ ឬប្រសិនបើមានវិការៈដ៏សំខាន់នៅក្នុងដំណើរការនីតិវិធី ពីមុន ដែលអាចប៉ះពាល់ដល់លទ្ធផលនៃសំណុំរឿង។ ៣. ពុំមានបដិប្បញ្ញត្តិពីមាត្រានេះ ត្រូវបានធ្វើឡើងនៅក្រោមមាត្រា ១៥ នៃអនុសញ្ញាឡើយ”។

[៥៣] អនុសញ្ញាដែលអនុវត្តកិច្ចព្រមព្រៀង Schengen ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៥ រវាងរដ្ឋាភិបាលនៃបណ្តារដ្ឋ នៃសហជីពសេដ្ឋកិច្ច Benelux សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងសាធារណរដ្ឋបារាំង ស្តីពីការលុបបំបាត់ចោលជាបណ្តើរៗនៃការត្រួតពិនិត្យនៅព្រំប្រទល់រួមរបស់បណ្តារដ្ឋទាំងនោះ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩០ មាត្រា ៥៤-៥៨។

00700483



សហប្រតិបត្តិការអន្តររដ្ឋបែបបុរាណនៅក្នុងបញ្ហាផ្នែកព្រហ្មទណ្ឌ ត្រូវបានដាក់ជំនួសដោយសហប្រតិបត្តិការតុលាការដែលត្រូវបានកែលម្អ ដោយផ្ទាល់រវាងតួអង្គនៃប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ។ លើសពីនេះទៀត បច្ចុប្បន្ននេះ តួអង្គទាំងនេះត្រូវតែទទួលស្គាល់នូវសេចក្តីសម្រេចរបស់តុលាការទៅវិញទៅមក ដោយផ្អែកទៅលើគោលការណ៍នៃការទទួលស្គាល់ទៅវិញទៅមក។ ជាលទ្ធផល បច្ចុប្បន្ននេះទិដ្ឋភាពដ៏សំខាន់នៃដំណើរការប្រព័ន្ធយុត្តិធម៌ ផ្នែកព្រហ្មទណ្ឌកំពុងតែកើតមាននៅក្នុងតំបន់អឺរ៉ុប ដោយពុំមានព្រំដែនកម្រិតខាងក្នុងឡើយ ដែលជាតំបន់តុលាការអន្តរប្រទេស។ តាមរយៈសេចក្តីសម្រេចលើក្របខ័ណ្ឌគតិយុត្តិជាច្រើន គោលការណ៍នៃការទទួលស្គាល់ទៅវិញទៅមកត្រូវបានបង្កើតឡើងសម្រាប់សេចក្តីសម្រេចរបស់តុលាការមុនពេលជំនុំជម្រះក្តី ដូចជា ការរឹបអូស ការប្រមូលភ័ស្តុតាង និងការចាប់ខ្លួន។ សេចក្តីសម្រេចរបស់តុលាការនៅក្នុងរដ្ឋសមាជិកមួយ មានអានុភាពគតិយុត្តិនៅក្នុងតំបន់ស្របច្បាប់របស់សហគមន៍អឺរ៉ុប។ សេចក្តីសម្រេចលើក្របខ័ណ្ឌគតិយុត្តិ ដ៏ល្បីល្បាញបំផុតនៅក្នុងបរិបទនេះគឺប្រាកដជាដីកាបង្គាប់ឱ្យនាំខ្លួនអឺរ៉ុប (European Arrest Warrant) ដែលដាក់ជំនួសនីតិវិធីបត្យាប័នបែបបុរាណ។ <u>ការទទួលស្គាល់ទៅវិញទៅមកនូវដីកាបង្គាប់ឱ្យនាំខ្លួនរបស់រដ្ឋនីមួយៗ មិនត្រឹមតែធ្វើឱ្យជនជាប់សង្ស័យប្រគល់ខ្លួនបានឆាប់រហ័សជាងមុនប៉ុណ្ណោះទេ នៅក្នុងសហគមន៍អឺរ៉ុប ប៉ុន្តែក៏បានធ្វើឱ្យគោលការណ៍ច្បាប់ ដូចជា គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ត្រូវបានយកមកអនុវត្តជាអន្តរប្រទេសផងដែរ</u>[៥៤]។

## គ. "បទដ្ឋាននីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ" ហាមឃាត់ការចោទប្រកាន់នាពេលបច្ចុប្បន្នទៅលើលោក អៀង សារី

២៥. អង្គបុរេជំនុំជម្រះបានសម្រេចដោយភ័ន្តច្រឡំថា អង្គបុរេជំនុំជម្រះគួរតែអនុវត្តតាមបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ ដែលមានការលើកលែងមួយចំពោះគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នៅពេលដែលការជំនុំជម្រះទោសកាលពីលើកមុនមិនបានដំណើរការដោយឯករាជ្យ និងអនាគតិ។ អង្គបុរេជំនុំជម្រះពុំចាំបាច់ពិចារណាអំពីបទដ្ឋាននីតិវិធីដែលបង្កើតឡើងនៅកម្រិតអន្តរជាតិឡើយ ពីព្រោះក្រមព្រហ្មទណ្ឌកម្ពុជា និងកតិកាសញ្ញា ICCPR អនុវត្តដើម្បីរារាំងការចោទប្រកាន់ជាថ្មីម្តងទៀត។ ប្រសិនបើការពិចារណាអំពីបទដ្ឋាននីតិវិធីទាំងនោះមានលក្ខណៈ

---

[៥៤] John A.E. Vervaele, *The Transnational* Ne Bis in Idem *Principle in the EU Mutual Recognition and Equivalent Protection of Human Rights*, 1(2) UTRECHT L. REV. 100, 101 (2005)។

ចាំបាច់ បទដ្ឋាននីតិវិធីដ៏សមស្របដើម្បីយកមកអនុវត្តនោះ គឺបទដ្ឋាននីតិវិធីដែលមានចែងនៅក្នុង មាត្រា ២០(៣)(ខ) នៃលក្ខន្តិកៈតុលាការ ICC ដែលមិនអនុញ្ញាតឲ្យមានការជំនុំជម្រះទោសជាថ្មីទៀតឡើយ នៅពេលដែលការជំនុំជម្រះទោសកាលពីមុនមិនបានដំណើរការដោយឯករាជ្យ និងអនាគតិ លើកលែងតែការជំនុំជម្រះទោសនោះ "មិនស្របតាមចេតនានាំខ្លួនជនដែលពាក់ព័ន្ធនោះមករកយុត្តិធម៌ផងដែរ"[៥៥]។

២៦. អង្គបុរេជំនុំជម្រះពិចារណាអំពី "បទដ្ឋាននីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ" ដើម្បីកំណត់ថាតើគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នឹងរារាំងការចោទប្រកាន់លោក អៀង សារី ឬយ៉ាងណា ពីព្រោះមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក តម្រូវឲ្យ អ.វ.ត.ក ៖

> ធានាថាការជំនុំជម្រះទោសត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី។ ប្រសិនបើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

២៧. បទដ្ឋាននីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិមិនចាំបាច់យកមកអនុវត្ត នៅក្នុងស្ថានភាពបច្ចុប្បន្នឡើយ ពីព្រោះនីតិវិធីជាធរមានដែលមានស្រាប់ (ក្រមព្រហ្មទណ្ឌកម្ពុជា និងកតិកាសញ្ញា ICCPR) ចែងអំពីបញ្ហាចំពោះមុខ ហើយពុំមានមន្ទិលឡើយទាក់ទិននឹងភាពស្របគ្នាជាមួយនឹងបទដ្ឋានអន្តរជាតិ។ ម្យ៉ាងវិញទៀត ប្រសិនបើអនុវត្តក្រមព្រហ្មទណ្ឌកម្ពុជា និងកតិកាសញ្ញា ICCPR នោះបទដ្ឋាននីតិវិធីអន្តរជាតិមិនអាចអនុវត្តបានឡើយ ហើយប្រាកដជាមិនត្រូវបានគេយកមកពិចារណា ឬជ្រើសរើសយក ជាជាងច្បាប់ជាធរមានដែលមានស្រាប់នោះឡើយ។

២៨. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាចាំបាច់ ក្នុងការពិចារណាអំពីបទដ្ឋាននីតិវិធីដែលបង្កើតនៅកម្រិតអន្តរជាតិ លក្ខន្តិកៈតុលាការ ICC ប្រាកដជាត្រូវបានជ្រើសយកជាជាងលក្ខន្តិកៈនៃ*តុលាការមិនអចិន្ត្រៃយ៍*នានា និងតុលាការពិសេសសម្រាប់ប្រទេសលីបង់។ លក្ខន្តិកៈតុលាការ ICC

---

[៥៥] លក្ខន្តិកៈតុលាការ ICC មាត្រា ២០(៣)(ខ)។

ដែលជាសន្ធិសញ្ញាមួយចុះហត្ថលេខាដោយរដ្ឋដែលជាសមាជិកចំនួន១១៥ គឺតំណាងឱ្យកិច្ចព្រមព្រៀងជាឯកច្ឆន្ទជាអន្តរជាតិ ជាជាងលក្ខន្តិកៈរបស់*តុលាការមិនអចិន្ត្រៃយ៍*នានា និងតុលាការពិសេសសម្រាប់ប្រទេសលីបង់។ លក្ខន្តិកៈតុលាការ ICC ក៏ត្រូវបានចុះហត្ថលេខាផងដែរដោយប្រទេសកម្ពុជា ដោយឡែកប្រទេសកម្ពុជា ពុំបានជាប់ពាក់ព័ន្ធជាមួយនឹងការធ្វើសេចក្តីព្រាងលក្ខន្តិកៈដែលអនុវត្តនៅ*តុលាការមិនអចិន្ត្រៃយ៍*នានា និងតុលាការពិសេសសម្រាប់ប្រទេសលីបង់ឡើយ។

## ឃ. ការជំនុំជម្រះឆ្នាំ១៩៧៩

២៩. អង្គជំនុំជម្រះសាលាដំបូងបានស្នើឱ្យក្រុមមេធាវីការពារក្តីលើកឡើងឱ្យបានជាក់លាក់ថាតើ "ការជំនុំជម្រះកាលពីឆ្នាំ១៩៧៩ របស់តុលាការបដិវត្តន៍ប្រជាជនធ្វើឡើងស្របតាមបទដ្ឋានត្រឹមត្រូវដែរឬទេ រួមទាំងក្របខ័ណ្ឌគតិយុត្តដែលតុលាការនេះលើកយកមកជាបង្អែក"[៥៦]។ ក្រុមមេធាវីការពារក្តីពុំដែលបានអះអាងថា ការជំនុំជម្រះកាលពីឆ្នាំ១៩៧៩ ជាការជំនុំជម្រះគំរូឡើយ។ ក្រុមមេធាវីការពារក្តីយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់ធ្វើការកំណត់ថាតើការជំនុំជម្រះកាលពីឆ្នាំ១៩៧៩ ធ្វើឡើងស្របតាមបទដ្ឋានត្រឹមត្រូវ ឬយ៉ាងណានោះឡើយ ពីព្រោះពុំមានការលើកលែងឡើយនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា និងកតិកាសញ្ញា ICCPR ដែលនឹងអនុញ្ញាតឱ្យមានការចោទប្រកាន់នាពេលបច្ចុប្បន្ននេះ ប្រសិនបើការជំនុំជម្រះទោសលោក អៀង សារី កាលពីឆ្នាំ១៩៧៩ មិនត្រូវបានធ្វើឡើងស្របតាមបទដ្ឋានត្រឹមត្រូវនោះ។ ទោះបីជាយ៉ាងណាក៏ដោយ វាគួរឱ្យកត់សម្គាល់ដែលថា ព្រះមហាក្សត្របានផ្តល់ព្រះរាជប្រទានលើកលែងទោស ដែលត្រូវបានអនុម័តដោយសភាជាតិ ចំពោះទោសដែលលោកអៀង សារី បានទទួលក្នុងឆ្នាំ១៩៧៩ ដែលបង្ហាញឱ្យឃើញថា រដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់សុពលភាពនៃការជំនុំជម្រះកាលពីឆ្នាំ១៩៧៩ នៅក្នុងឆ្នាំ១៩៩៦[៥៧]។ តាមដែលក្រុមមេធាវីការពារក្តីបានដឹងគឺថា នៅពេលនោះពុំមាននរណាម្នាក់នៅក្នុងសហគមន៍អន្តរជាតិបានលើកនូវបញ្ហាថា ការជំនុំជម្រះកាលពីឆ្នាំ១៩៧៩ ពុំមានសុពលភាពនោះឡើយ។

---

[៥៦] អនុស្សរណៈ កម្មវត្ថុ៖ ការដាក់អញ្ញត្រកម្មបន្ថែម (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ) ថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ E51/9។

[៥៧] សូមមើលបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ ឯកសារ D427/1/6 កថាខណ្ឌ ៥១-៦២ សម្រាប់ការពិភាក្សាអំពីសារតា ស្តីអំពីការផ្តល់នូវការលើកលែងទោស និងអនុគ្រោះទោស។

៣០. វាគួរឱ្យកត់សម្គាល់ទៀតថា កំហុសឆ្គងមួយចំនួននៅក្នុងការជំនុំជម្រះកាលពីឆ្នាំ១៩៧៩ ដែលអង្គបុរេជំនុំជម្រះបានកត់សម្គាល់នោះមានភាពស្រដៀងគ្នាទៅនឹងកំហុសឆ្គងដែលកើតមាននៅ អ.វ.ត.ក នាពេលបច្ចុប្បន្ននេះ។ ឧទាហរណ៍ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ចៅក្រមមួយចំនួនជាប់ពាក់ព័ន្ធទៅនឹងអង្គនីតិប្រតិបត្តិរបស់រដ្ឋាភិបាល[៥៨]។ នៅ អ.វ.ត.ក មានការចោទប្រកាន់ជាច្រើនដែលថា ចៅក្រមខ្លះស្ថិតក្រោមការគ្រប់គ្រងពីអង្គនីតិប្រតិបត្តិ ឬពីរដ្ឋាភិបាលផ្ទាល់របស់ពួកគាត់ ដោយផ្អែកទៅលើសេចក្តីថ្លែងការណ៍មួយចំនួនរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន[៥៩] ព្រមទាំងផ្អែកទៅលើសេចក្តីសម្រេចមួយចំនួនដែលចៅក្រមទាំងនោះបានសម្រេច ដែលហាក់ដូចជាមានហេតុផលនយោបាយ ឬពុំមានឯករាជ្យភាព[៦០]។ អង្គបុរេជំនុំជម្រះបានពិចារណាថា ការមិនបានបែងចែកឱ្យដាច់ពីគ្នារវាងអង្គនីតិប្រតិបត្តិ និងស្ថាប័នតុលាការ គឺជាសញ្ញាប្រាប់ឱ្យដឹងថាការជំនុំជម្រះកាលពីឆ្នាំ១៩៧៩ មិនត្រូវបានធ្វើឡើងស្របតាមបទដ្ឋានត្រឹមត្រូវឡើយ។ ប៉ុន្តែការវាយតម្លៃរបស់អង្គបុរេជំនុំជម្រះអំពីការបែងចែកអំណាច មិនអាចឆ្លុះបញ្ចាំងអំពីលក្ខណៈវិនិច្ឆ័យដ៏សមស្របសម្រាប់ភាពមិនលម្អៀង និងភាពអនុលោមតាមបទដ្ឋានត្រឹមត្រូវនៅក្នុងបរិបទរដ្ឋាភិបាលកុម្មុយនីស្តក្នុងឆ្នាំ១៩៧៩ ឡើយ។ ឧទាហរណ៍ មជ្ឈការនៃការគ្រប់គ្រងផ្នែកនយោបាយ រួមទាំងការលុបបំបាត់ចោលនូវការបែងចែកអំណាច គឺជាលក្ខណៈពិសេសនៃរដ្ឋាភិបាលកុម្មុយនីស្ត<u>រហូតមកដល់បច្ចុប្បន្ននេះ</u> និងមិនអាចចាត់ទុកបានថា ការ

---

[៥៨] សាលដីការបស់ អ.ប.ជ កថាខណ្ឌ ១៦៧។

[៥៩] សូមមើល ឧទាហរណ៍ សំណុំរឿង អៀង សារី ០០២-២០-១០-២០០៩- អវតក (អ.ប.ជ០៣) សំណើរបស់ អៀង សារី សុំឱ្យមានវិធានការសមរម្យ ទាក់ទងនឹងសេចក្តីថ្លែងការណ៍មួយចំនួនរបស់ នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលតតាំងនឹងឯករាជ្យភាពរបស់ចៅក្រម អង្គបុរេជំនុំជម្រះ គឺចៅក្រម Katinka LAHUIS និងចៅក្រម Rowan DOWNING។

[៦០] សូមមើល ឧទាហរណ៍ សំណើរបស់លោក អៀង សារី គាំទ្រសំណើរបស់លោកស្រី អៀង ធីរិទ្ធ សុំដិតចិត្តចៅក្រម យូរ ឧត្តរា ពីអង្គចៅក្រមពិសេសដោយសារកង្វះឯករាជ្យភាព និងសំណើសុំឱ្យមានសវនាការជាសាធារណៈ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១ ឯកសារ E63/1។ Alex Bates, *Transitional Justice in Cambodia: Analytical Report*, ATLAS PROJECT, October 2010 កថាខណ្ឌ ១៤៥។ ចៅក្រមជំនុំជម្រះ និល ណុន ត្រូវបានដកស្រង់ពាក្យសម្តីដែលបញ្ជាក់ថា "***យើងក៏មានបញ្ហាផងដែរ ពីព្រោះចៅក្រមពុំមានឯករាជ្យភាពឡើយក្នុងប្រទេសកម្ពុជា [រដ្ឋាភិបាល] តំរាមកំហែង និងដាក់សម្ពាធទៅលើចៅក្រម ចៅក្រមទទួលលុយដូច្នេះទាំងអស់នេះមិនល្អណាស់ណាទេ***"។ (សេចក្តីបញ្ជាក់បន្ថែម)

ជំនុំជម្រះកាលពីឆ្នាំ១៩៧៩ ពុំមានឯករាជ្យភាព និងអនាគតិនោះឡើយ[61]។

## III. **សំណូមពរ**

**អាស្រ័យហេតុនេះ** ដោយយោងទៅលើហេតុផលទាំងអស់ដែលបានបញ្ជាក់នៅក្នុងសំណើនេះ មេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចថា គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*រារាំងការចោទប្រកាន់លើលោក អៀង សារី នៅ អ.វ.ត.ក។

---

៦១ ឧទាហរណ៍ នៅក្នុងសាធារណរដ្ឋប្រជាមានិតចិន ការបែងចែកអំណាចត្រូវបានវិភាគក្នុងពាក្យពេចន៍ខាងក្រោមនេះ៖ "អ្នកខ្លះ... ចាត់ទុកថា មានតែ "ការបែងចែកអំណាច (បី) ប៉ុណ្ណោះ គឺជាលទ្ធិប្រជាធិបតេយ្យពិតប្រាកដ និងអាចធានា នូវប្រតិបត្តិការល្អនៃប្រព័ន្ធនយោបាយ ដូច្នេះ ពួកគេគាំទ្រការយកគំរូតាមបស្ចិមប្រទេស និងអនុវត្តការត្រួតពិនិត្យមើល និងការថ្លឹងអំណាច។ អ្នកជ្រុលនិយមខ្លះចាត់ទុកការបែងចែកអំណាចថាជា ទម្រង់ "ប្រជាធិបតេយ្យ" បំផុតរបស់រដ្ឋាភិបាល។ ពិតណាស់ ភាពមិនសមទំនងនេះគឺមានភាពលម្អៀង។ តាមពិត ការបែងចែកអំណាចពិតជាអាចទប់ស្កាត់ក្រុម មួយដែលត្រូវបានបង្កើតឡើង មិនឱ្យទទួលបានផ្តាច់មុខ ឬទាមទារយកដោយផ្នែកខ្លះ នូវអំណាចទាំងអស់មកកាន់កាប់ឡើយ ដូច្នេះ "ប្រជាធិបតេយ្យ" ត្រូវបានធានាសម្រាប់ក្រុមដែលកាន់អំណាច។ ទោះបីជាយ៉ាងណាក៏ដោយ ទម្រង់រដ្ឋាភិបាលនេះ មិនត្រូវបានបង្កើតឡើងដើម្បីធានានូវសិទ្ធិប្រជាធិបតេយ្យរបស់ប្រជាជនឡើយ។ អ្នកខ្លះអះអាងថា ប្រព័ន្ធនៃការបែងចែងអំណាចអាចមានលទ្ធភាពការពារប្រឆាំងនឹងអំពើពុករលួយ ហើយប្រការនេះ [sic] មិនស្របគ្នាជាមួយ នឹងអង្គហេតុឡើយ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅ ឈ្មួញអាវុធប្រាំមួយនាក់ រួមទាំង Boeing និង Lockheed ត្រូវបានផ្តល់នូវការចុះកិច្ចសន្យាជាច្រើនដែលមានទឹកប្រាក់រាប់កោដិដុល្លារ ដោយទទួលបានប្រាក់ចំណេញដោយផ្ទាល់ និងដោយប្រយោលយ៉ាងច្រើនចំពោះការបញ្ចុះបញ្ចូល [sic] Capitol Hill ហើយជំនួញដ៏សម្ងាត់ខុសច្បាប់បែបនេះ ដែលបង្ហាញឱ្យឃើញមកដល់ពេលបច្ចុប្បន្ននេះ គឺគ្រាន់តែជាផ្នែកដ៏តូចមួយប៉ុណ្ណោះនៃ "បញ្ហាដ៏ធំ"។ អ្នកគាំទ្រការបែងចែកអំណាចខ្លះពិពណ៌នា "ការបែងចែកអំណាច" ថាជាអនុសញ្ញាអន្តរជាតិ ដែលមានលក្ខណៈជាសកល ដូច្នេះប្រទេសចិនគួរតែអនុវត្តដូចគ្នាផងដែរ។ សញ្ញាណនេះក៏ពុំមានហេតុផលផងដែរ។ វាត្រូវ តែមានការចង្អុលបង្ហាញថា ពុំមានមូលដ្ឋានផ្នែកសង្គម និងនយោបាយ [sic] ឡើយ សម្រាប់បែងចែកអំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ នៅក្នុងប្រទេសចិន ចុះទម្រាំមូលដ្ឋានសេដ្ឋកិច្ច និងមូលដ្ឋានវណ្ណៈទៀតនោះ។ ប្រសិនបើចិនយកគំរូប្រព័ន្ធនយោបាយដែលមានការបែងចែកអំណាចតាមប្រទេសមូលធន ដោយប្រឆាំងនឹងស្ថានភាពជាតិផ្ទាល់របស់ខ្លួន និងផលប្រយោជន៍ជាមូលដ្ឋានរបស់ប្រជាជនខ្លួន មូលដ្ឋាននៃស្ថេរភាពនយោបាយរបស់ខ្លួននឹងត្រូវបានប៉ះពាល់ ប្រទេសចិននឹងធ្លាក់ចូលទៅក្នុងភាពចលាចល ហើយប្រជាជននឹងទទួលរងទុក្ខផងដែរ។ ដូច្នេះ វាមានសារៈសំខាន់ណាស់សម្រាប់ប្រទេសចិនក្នុងការប្រកាន់ខ្ជាប់នូវការឯកភាពពិតប្រាកដនៃថ្នាក់ដឹកនាំបក្ស ប្រជាជនដែលសន្មតថាជាចៅហ្វាយនៃជោគវាសនាផ្ទាល់ខ្លួនរបស់ពួកគេ និងការចាត់ចែងកិច្ចការរដ្ឋ ស្របតាមច្បាប់។ ការអនុវត្តដ៏មានសារៈសំខាន់នេះ ផ្តល់នូវភ័ស្តុតាងយ៉ាងច្បាស់ថា ប្រជាជននៅក្នុងប្រទេសត្រូវតែប្រកាន់ខ្ជាប់ចំណុចនេះ និងមិនត្រូវងាករេឡើយ..." *NPC system to be adhered to and further improved*, PEOPLE'S DAILY ONLINE, 19 June 2009 អាចរកមើលបាននៅគេហទំព័រ http://english.peopledaily.com.cn/90001/90780/6682417.html (សេចក្តីបញ្ជាក់បន្ថែម)។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្ដីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី